INNOVATION FOR CHANGE
EAST ASIA

រឿងរ៉ាវ
អំពីផលប៉ះពាល់ចេញពី
គម្រោងខ្សែក្រវ៉ាត់និងផ្លូវរបស់
ប្រទេសចិន

# កសិករកម្ពុជា
## ជាមួយនឹង ព្រៃឈើនិងត្រី ដែលកំពុងបាត់បង់បណ្តើរៗ




គំនូរនិងសាច់រឿង ដោយ សៅ ស្រីម៉ៅ និង សាយ តុលា
ស្រាវជ្រាវដោយដៃគូសហគមន៍មូលដ្ឋាន


ពិសិដ្ឋជាបុគ្គលិកហាត់ការនៅស្ថាប័នកាសែតមួយកន្លែងក្នុងរាជធានីភ្នំពេញ។ ស្អែកនេះ
ជាលើកទីមួយដែលគាត់ត្រូវចុះទៅស្រុកវាលវែង នាខេត្តពោធិ៍សាត់
ដើម្បីសរសេរពីបញ្ហាដែលកើតចេញពីការសាងទំនប់វារីអគ្គិសនីនៅទីនោះ។
ប្អូនគួរតែចាប់យកឱកាសនេះដើម្បីកសាងសមត្ថភាពរបស់ខ្លួន។
បងជឿថាប្អូនអាចធ្វើបាន!
នៅថ្ងៃបន្ទាប់
ថ្មើរណាទើបដល់ផ្ទះពូសៅ ពូ?
ទ្រាំតិចទៅក្មួយអើយ ជិតដល់ហើយ!


ពូសៅៗ! ខ្ញុំមកហើយពូ!”
អូហ៍ ពិសិដ្ឋ! មកទុកដាក់អីវ៉ាន់សិនទៅក្មួយ នឹងអាលបានញ៉ាំបាយជាមួយពួកយើង
បាទពូ! កំពុងតែឃ្លានស្រាប់ផង!
ពិសិដ្ឋ! ឯងញ៉ាំឱ្យច្រើនៗទៅណា៎ កុំលាក់ពោះអី!
ពីមុនផ្លូវដែលឯងជិះមកមិនយ៉ាកអ៊ីចឹងទេ
តែមកពីអាឡានដឹកដី ដឹកឈើហ្នឹង ទើបធ្វើឱ្យខូចផ្លូវអស់។
ឯងប្រហែលជាកើតខ្យល់ដោយសារតែផ្លូវហ្នឹងហើយ!
“ ”
...


អើយ ពិសិដ្ឋ! ពូគិតទៅរករកត្រីនៅឯភូមិខាងនោះ ព្រោះស្ទឹងក្រោយផ្ទះនេះគ្មានត្រីទៀតទេ។ ឯងចង់ទៅជាមួយពូទេ?
ចាំខ្ញុំផងពូ ខ្ញុំទៅដែរ!
ឡើងម៉ូតូឱ្យស្រួលបួលមក ហើយជួយកាន់សំណាញ់ និងទ្រូឱ្យពូផង!
ទាល់តែក្រោកពីព្រឹកទើបបាន ព្រោះចាំតែថ្ងៃបន្តិច ថ្ងៃក្តៅដូចគេហែកមេឃ!


យី! អ្នកទារលុយនេះមកចំពេលតែម្តងហើយ!
ពិសិដ្ឋ! ឯងជជែកជាមួយមីងភាពសិនទៅ ពូទៅរកបង់ត្រីនៅបឹងឯក្រោយហើយ
មីងភាព! ពូសៅមើលទៅដូចជាប្រញាប់ប្រញាល់ដល់ហើយ!
ពិសិដ្ឋអើយ! ពូសៅនិង អ្នកភូមិនេះជំពាក់លុយធនាគារស្ទើរតែគ្រប់គ្នាហ្នឹង។ ដោយសារ មិនចង់ចំណាកស្រុកដូចគេ យើងគិតថាយកលុយមកធ្វើចម្ការក្រូច តែបែរជាគ្មានបានផលអីបន្តិចសោះ!
ម៉េចអ៊ីចឹងមីង?
ព្រោះតាំងពីគេធ្វើទំនប់មក ដីក៏ប្រែខ្សោះអស់ជីវជាតិ ហើយមេឃនោះ ក៏កាន់តែក្តៅឡើងៗ។ ខ្យល់ព្យុះក៏កើតមានឡើងជារៀងរាល់ឆ្នាំ ព្រោះ ព្រៃឈើមិនក្រាស់ៗដូចមុន! ឯក្រូចយើងវិញក៏ស្កុកលក់មិនចេញទេ!


ពូសៅៗ! ខ្ញុំសម្អាតចប់ហើយ។ បានត្រីច្រើនទេ ពូ?
អើយ... ត្រីក៏អត់ ព្រៃក៏ខ្សត់...
តើឱ្យជីវិតពូរំពឹងស្អីបានទៀត?
បានមួយសម្លរដែរតើ ពូ!
តែពីមុនវាមុនអ៊ីចឹងទេ!
សម្បូរណាស់ក្មួយអើយ


ក្រោយផ្លូវធ្វើហើយ មានមនុស្សម្នាជាច្រើនមកលេងភ្នំនៅជួរភ្នំវាលវែងនេះមិនដាច់។ គេរីករាយណាស់ តែគេប្រហែលមិនបានគិតថាដោយសារតែផ្លូវមួយខ្សែនេះ អស់ព្រៃ ជីវៈចម្រុះ និងសត្វព្រៃប៉ុន្មានក្បាលទេ។
នេះៗ! កាលពី១៥ឆ្នាំមុន ម្តុំហ្នឹងមានព្រៃក្រាស់ឃ្មឹក ពួសឹងមិនហ៊ានចេញមកតំបន់នេះផង។ កន្លែងច្រកណាក៏សុទ្ធតែផ្ទះៗ!
ពេលដែលក្រុមហ៊ុនចូលមកកសាងផ្លូវ និងទំនប់នេះ ពូបានឃើញរឿងអយុត្តិធម៌ច្រើនណាស់ តែអ្នកស្រុកអ្នកភូមិ ដូចពូបានត្រឹមតែឈរសម្លឹង ធ្វើអីគេមិនកើតទេ!


ដោយសារអ្នកភូមិខ្លះមានជីវភាពខ្សត់ខ្សោយ ពួកគេបានទៅស៊ីឈ្នួលបាញ់សត្វ និងកាប់ឈើខុសច្បាប់ ដើម្បីលក់ឱ្យឈ្មួញដែលមានអំណាចទាំងនោះ។ អ្នកខ្លះក៏កបទៅ តែអ្នកខ្លះក៏គ្រោះថ្នាក់រហូតដល់បាត់បង់ជីវិតក៏មាន!
អ្នកភូមិយើងខ្លះដឹកឈើតាមម៉ូតូ ហើយខ្លះដឹកតាមគោយន្ត ទៅតាមលទ្ធភាពដែលគេមាន ទៅដាក់នៅឃ្លាំងស្តុកឈើ។
អ្នកភូមិនេះសុទ្ធតែដឹងថា ឈ្មួញទិញឈើប្រណីតៗទាំងនោះដើម្បីលក់ទៅវៀតណាមក្នុងតម្លៃដ៏សែនថ្លៃ។ ប៉ុន្តែ តើយើងអាចធ្វើស្អីបាន?


យី! អ្នកទារបំណុលនេះ មកចាំទារទាល់តែបានហើយមើលទៅ!
ពូសៅ! ខ្ញុំមកចាំពូមួយសន្ទុះហើយ។ ល្អណាស់ដែលពូមកចំពេលល្មម!
លោកប្អូន! ឱ្យខ្ញុំទៅរកលុយណាមកសងប្អូនបាន។ មើលចុះ! ក្រូចខ្ញុំចេញផ្កាល្អ តែផ្លែមករលួយ ហើយខ្លះស្កកគ្មានទឹកទេ។
ប្អូនឯងមើលចុះ! ជ្រុះពេញក្រោមដើមហើយ!


ហ៊ឹម! គិតទៅរាល់ការអភិវឌ្ឍទាំងអស់មិនមែនសុទ្ធតែហុចផលដល់អ្នកភូមិទេ! តើឱ្យពួកគាត់រកច្រកចេញតាមវិធីណា?
មិនបាច់គិតច្រើនទេ ពិសិដ្ឋអើយ! នេះហើយជាជីវិតអ្នកតំបន់នេះ។ រាល់ថ្ងៃពូ និងអ្នកភូមិដទៃទៀត សង្ឃឹមថាគេនឹងផ្តល់សំណងសមរម្យដល់ពួកយើង។ ដែលអាចឱ្យពួកយើងសងលុយធនាគារ នឹងអាលនាំកូនចៅទៅកសាងជីវិតថ្មីនៅកន្លែងផ្សេង។ យប់ជ្រៅហើយ ឯងប្រញាប់ចូលសម្រាកទៅ ព្រោះស្អែកត្រូវក្រោកពីព្រលឹមផង!
ខ្ញុំលាពូទៅសិនហើយ ពូសៅ! សង្ឃឹមថាគេជួយដោះស្រាយបញ្ហាឱ្យពូឆាប់ៗ


មិនគួរឱ្យជឿសោះថានៅខាងក្រោយនៃភាពស្រស់ស្អាតនៃតំបន់នីមួយៗ មានរឿងអយុត្តិធម៌ ពុករលួយ និងការរំលោភបំពានកើតមានច្រើនណាស់។
ខ្ញុំសង្ឃឹមថា សំណេររបស់ខ្ញុំអាចជាសម្លេងប្រាប់ពីតម្រូវការពិតប្រាកដរបស់មនុស្សក្នុងសហគមន៍ និងជួយឱ្យគាត់ទទួលបានយុត្តិធម៌។